**សេចក្តីព្រាង**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០២២
# និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

**ថ្ងៃអង្គារ ៣ កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦**
**សណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣**

## ១. សេចក្តីផ្តើម

ឆ្នាំ២០២២ កន្លងទៅនេះ ជំងឺកូវីដ-១៩ នៅបន្តឆ្លងរាលដាលទាំងក្នុងតំបន់ និងពិភពលោក។ ទន្ទឹមនឹងនេះ សភាពការណ៍អន្តរជាតិបន្តវិបត្តិយ៉ាងស្មុគស្មាញ ទាំងក្នុងក្របខណ្ឌតំបន់ និងពិភពលោក ដូចជា បញ្ហាសង្គ្រាមនៅអ៊ុយក្រែន នៅឧបទ្វីបកូរ៉េ កោះតៃវ៉ាន់ ជាបច្ច័យនៃការប្រកួតប្រជែងដ៏ស្រួចស្រាល់ តានតឹង និងគ្រោះថ្នាក់បំផុតរបស់មហាអំណាច ដែលធ្វើឱ្យធ្លាក់ចុះនូវកំណើនសេដ្ឋកិច្ច ជំរុញឱ្យមានអតិផរណា រាំងស្ទះខ្សែសង្វាក់ផ្គត់ផ្គង់ និងបញ្ហាអសន្តិសុខស្បៀងនិងថាមពល។ បញ្ហាទាំងអស់នេះបានជះឥទ្ធិពលអវិជ្ជមានទៅលើប្រទេសទាំងឡាយក្នុងពិភពលោករួមទាំងប្រទេសកម្ពុជាយើងផងដែរ។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងវិធានការជាច្រើនប្រកបដោយប្រសិទ្ធភាពធ្វើឱ្យជានាបាននូវស្ថិរភាព ជីវភាពសេដ្ឋកិច្ច-សង្គម។ យើងបន្តការពារបានយ៉ាងរឹងមាំនូវសុខសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ និងធ្វើឱ្យលេចត្រដែតឡើងនូវកិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ តាមរយៈវេទិកាធំៗជាច្រើនរួមទាំងជោគជ័យនៃដំណើរទស្សនកិច្ចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្រៅប្រទេស ពិសេសការអនុវត្តនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវគោលបំណងគោលនយោបាយចម្បងគឺ "**ការលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**"។ ដើម្បីឈានទៅសម្រេចបាននូវគោលបំណងនេះ ក្រសួងបានកំណត់គោលដៅយុទ្ធសាស្ត្រ ចំនួន ៤ ដែលដើរតួជាកម្មវិធីអាទិភាពគឺ៖ (១).ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ (២).ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ (៣).ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និង (៤).ការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ។ ទន្ទឹមនេះ ក្រសួងបានផ្តោតការយកចិត្តទុកដាក់លើការងារជាសារវន្តចំនួន ៧ គឺ (១).កែលម្អស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌រស់នៅរបស់

ប្រជាជនជនបទ (២).កាត់បន្ថយជាបណ្ដើរៗនូវភាពក្រីក្រនិងភាពខុសគ្នារវាងអ្នកជនបទនិងអ្នកទីក្រុង (៣).ជំរុញការបណ្ដុះបណ្ដាលវិជ្ជាជីវៈមូលដ្ឋានសំដៅបើកទូលាយដល់ប្រជាពលរដ្ឋជ្រើសរើសមុខរបរថ្មីបន្ថែម (៤).លើកកម្ពស់ផលិតភាពនិងប្រាក់ចំណូល (៥).អភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព (៦).កម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះថ្នាក់គ្រួសារ ភូមិ ឃុំ ដូចជា អភិវឌ្ឍន៍ផ្លូវជនបទ ការផ្គត់ផ្គង់ទឹកជនបទ ការថែរក្សាអនាម័យមូលដ្ឋាន ការអភិវឌ្ឍសហគមន៍ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និង (៧).ការពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទគ្រប់ជាន់ថ្នាក់។

ក្នុងរយៈកាល ៤ ឆ្នាំ កន្លងទៅនេះ ក្រសួងអភិវឌ្ឍន៍ជនបទ សម្រេចបានលទ្ធផលក្នុងឆ្នាំជាច្រើនគួរឱ្យកត់សម្គាល់ ទោះជាស្ថិតក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏ក្រសួងបាននិងកំពុងរួមចំណែកយ៉ាងសកម្មក្នុងការជំរុញឱ្យមានការផ្លាស់ប្ដូរជីវភាពរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្នទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន។

## ២. សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២២

ផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ ក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំ យកចិត្តទុកដាក់  អនុវត្តការងាររបស់ខ្លួនទទួលបានលទ្ធផលក្នុងឆ្នាំគួរឱ្យកត់សម្គាល់ទាំងផ្នែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ និងការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ដែលសមិទ្ធផលទាំងអស់នេះបាននិងកំពុងរួមចំណែករក្សាស្ថិរភាពលើកកម្ពស់កម្រិតជីវភាពសុខុមាលភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទ ជាអាទិ៍ក្នុងឆ្នាំ ២០២២ ក្រសួងសម្រេចបានសមិទ្ធផល ដូចតទៅ៖

### ២.១. ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍

ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍ដឹកជញ្ជូននៅជនបទ ពិតជាមានសារៈសំខាន់ណាស់ក្នុងការជំរុញដំណើរអន្តរកម្មផ្នែកសេដ្ឋកិច្ច សង្គមកិច្ច រវាងតំបន់ជនបទ និងទីប្រជុំជននៅកម្ពុជានាពេលបច្ចុប្បន្ន។ វិស័យនេះ គឺជាសរសៃឈាមសេដ្ឋកិច្ចដ៏សំខាន់ក្នុងការផ្សារភ្ជាប់សកម្មភាពធុរកិច្ចផ្សេងៗក្នុងប្រទេស និងក្នុងតំបន់ឱ្យមានភាពរស់រវើក និងកាន់តែសកម្មឡើងទៀត ក្នុងការជំរុញកំណើនប្រាក់ចំណូលរបស់ប្រជាជននៅជនបទ។ ឥឡូវនេះ ការលើកកម្រិតផ្លូវជនបទពីផ្លូវដី ទៅជាផ្លូវក្រាលក្រួសក្រហម ឬផ្លូវក្រាលកៅស៊ូ និងក្រាលបេតុង បានជួយសម្រួល និងផ្ដល់ផលប្រយោជន៍ជាច្រើនដល់ប្រជាជននៅជនបទ ដូចជា ងាយស្រួលក្នុងការធ្វើដំណើរ ចំណេញពេលវេលា កាត់បន្ថយការចំណាយក្នុងការដឹកជញ្ជូនសម្ភារ ទំនិញ ផលិតផលនានា ក៏ដូចជាកសិផលទៅកាន់ទីផ្សារ និងមានភាពងាយស្រួលក្នុងការទទួលបាននូវសេវាសាធារណៈផ្សេងៗ។ ការស្ថាបនា ការជួសជុល លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសាធារណៈផ្សេងៗទៀត បាននិងកំពុងនាំមកនូវកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាព ជូនដល់ប្រជាជនគ្រប់ទិសទីនៅទូទាំងប្រទេស ជាពិសេសតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះ ការតភ្ជាប់បណ្ដាញផ្លូវជនបទមិនត្រឹមតែបានបង្កភាពងាយស្រួលលើផ្នែកគមនាគមន៍ដឹកជញ្ជូនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្ដល់អត្ថប្រយោជន៍ដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនជនបទ ហើយជានិច្ចកាលតែងតែទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ។

ក្រោមហិរញ្ញប្បទានពីថវិកាជាតិ (**ភ្ជាប់ជូនក្នុងតារាងឧបសម្ព័ន្ធទី១**) ក្រសួងបានជួសជុល និងថែទាំផ្លូវជនបទចំនួន **៤២៦ ខ្សែ** ប្រវែង **៤ ២១៣ គ.ម**, បានស្ថាបនាពង្រីកវិសាលភាព និងកែលម្អលើក

កម្រិតផ្លូវជនបទប្រវែង **២៦១ គ.ម** និងសាងសង់សំណង់សិល្បការគ្រប់ប្រភេទ និងស្លាកសញ្ញាចរាចរណ៍ ចំនួន **៣ ០៩៤ កន្លែង**, គម្រោងសាច់ប្រាក់ពលកម្ម ស្តាបនាផ្លូវដីបានប្រវែង **៥៧៩ គ.ម** និងស្តាបនាផ្លូវក្រាលក្រួសក្រហមបានប្រវែង **៣៣៥ គ.ម** ។ លទ្ធផលនេះ បង្ហាញថាការងារស្តាបនា ថែទាំ ជួសជុល និងកែលម្អលើកកម្រិតផ្លូវជនបទ ក្រោមហិរញ្ញប្បទានពីថវិកាជាតិ សម្រេចបាន **៩៧%** ធៀបនឹងផែនការឆ្នាំ២០២២ (**៤ ៦០៩ គ.ម**) និង **៧៨%** (**៨ ៤៩៣ គ.ម**) ធៀបនឹងផែនការយុទ្ធសាស្ត្រថវិកា ៣ ឆ្នាំរំកិល ឆ្នាំ២០២១-២០២៣ (**១០ ៨៨៩ គ.ម**) ប៉ុន្តែលទ្ធផលនេះ ខ្ពស់ជាងឆ្នាំ២០២១ ប្រមាណ **១១,៣២%** (**៤៥៥ គ.ម**)។

ទន្ទឹមនឹងនេះ ក្រសួងក៏ទទួលបានការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូជាច្រើនដោយបានស្តាបនា និងកែលម្អលើកកម្រិតផ្លូវជនបទបានប្រវែង **៦៣៧,៤៦ គ.ម** និងសាងសង់សំណង់សិល្បការបានចំនួន **១ ១១៩ កន្លែង (ភ្ជាប់ជូនក្នុងតារាងឧបសម្ព័ន្ធទី២)**។ លទ្ធផលក្នុងឆ្នាំ២០២២ នេះមានសកម្មភាពមួយចំនួនយឺតយ៉ាវ ដោយសារគម្រោងខ្លះស្ថិតក្នុងដំណាក់កាលកំពុងសិក្សានិងអនុវត្តកិច្ចលទ្ធកម្ម និងដោយសារការបន្តរីករាលដាលនៃជំងឺកូវីដ-១៩។

## ២.២. ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ មានសារៈសំខាន់ណាស់ ក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជននៅតំបន់ជនបទ។ ជារួម លក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទត្រូវបានកែលម្អ និងមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ តាមរយៈការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត ការសម្អាត និងអនាម័យជនបទ។ សព្វថ្ងៃនេះ ជាទូទៅប្រជាជនជនបទទទួលបានសេវាមូលដ្ឋានសមរម្យ អនាម័យល្អ បរិស្ថានស្អាត មានផាសុកភាព ដែលបាននិងកំពុងចូលរួមចំណែកគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ។

ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រជាជននៅតំបន់ជនបទទទួលបានការអប់រំផ្សព្វផ្សាយឱ្យយល់ដឹងអំពីការផ្លាស់ប្តូរទម្លាប់ និងការកែលម្អលក្ខខណ្ឌនៃការរស់នៅប្រកបដោយផាសុកភាព និងសុវត្ថិភាព តាមរយៈការធ្វើអនាម័យផ្ទាល់ខ្លួនតាមក្បួនខ្នាតត្រឹមត្រូវ ជាពិសេស ការអនុវត្តវិធានការ ៣កុំ និង៣ការពារ បានខ្ជាប់ខ្ជួន នាអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩។

ក្រសួងអភិវឌ្ឍន៍ជនបទ បាននិងកំពុងបន្តអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទជំហានទី ២ (២០១៩-២០២៣) ដោយកំណត់យកនូវគោលដៅអត្រាគ្របដណ្តប់ចំនួន ៩០% ត្រឹមឆ្នាំ២០២៣ លើការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ។ គិតត្រឹមឆ្នាំ២០២១ កន្លងទៅ បើទោះជាស្ថិតក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏អត្រាគ្របដណ្តប់ លើការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ សម្រេចបានកើនឡើងរហូតដល់ជិត ៨០%។ សម្រាប់ឆ្នាំ២០២២ នេះ លទ្ធផលសម្រេចបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់ជនបទ បានបន្តកើនឡើងរហូតដល់ជាង ៨០% ខណៈការជំរុញកំណើននៃអត្រាទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតកើនឡើងប្រមាណ ២% និងអនាម័យនៅតំបន់ជនបទ កើនឡើងប្រមាណ ១,៥% ជារៀងរាល់ឆ្នាំគិតចាប់ពីឆ្នាំ២០១៧។

ចំពោះការលើកកម្ពស់ការរស់នៅស្អាត និងអនាម័យ ក្រសួងបានបង្កើតយន្តការថ្នាក់ជាតិសហការជាមួយថ្នាក់ក្រោមជាតិ អនុវត្តកម្មវិធី**បញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល** (Open Defecation Free-ODF)។ គិតត្រឹមឆ្នាំ២០២២ កម្មវិធី ODF សម្រេចបាន ៖ ៦ ០២៨ ភូមិ ៤៧២ ឃុំ ៣៩ ស្រុក និងខេត្ត

ចំនួន ០៣ គឺខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តកណ្តាល ហើយខេត្តចំនួន ០៣ ទៀត គឺខេត្តកំពង់ឆ្នាំង ខេត្តកែប និងខេត្តកំពង់ស្ពឺ កំពុងមានសុទិដ្ឋិនិយមនិងបញ្ចប់នៅក្នុងឆ្នាំថ្មីនេះ រួមជាមួយភូមិដែលទទួលបានសេវាទឹកស្អាតសម្រាប់ប្រើប្រាស់សរុបចំនួន ១១ ៥៩២ ភូមិ ១ ១៥៦ ឃុំ និង ៤៩ ស្រុក។ ទន្ទឹមនេះ ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានរៀបចំឯកសារគតិយុត្តិមួយចំនួនលើវិស័យផ្គត់ផ្គង់ទឹកជនបទ ដែលមានដូចជា ៖ គោលការណ៍ណែនាំ ស្តីពីការឧបត្ថម្ភធនសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រនៅតំបន់ជនបទ, គោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ, សៀវភៅណែនាំបច្ចេកទេស ស្តីពីស្រះសហគមន៍, សៀវភៅណែនាំបច្ចេកទេស ស្តីពីអណ្តូងស្នប់អាហ្វ្រីដេវ, សៀវភៅណែនាំបច្ចេកទេស ស្តីពីប្រព័ន្ធប្រមូលទឹកភ្លៀងលក្ខណៈគ្រួសារ និងសាលារៀន និងសៀវភៅណែនាំបច្ចេកទេសចំនួន ០៣ ទៀត ដែលមានដូចជា៖ សៀវភៅណែនាំបច្ចេកទេស ស្តីពីប្រពន្ធ័ចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ដែលប្រើប្រាស់ប្រភពទឹកលើដី ប្រភពទឹកក្រោមដី និងប្រភពទឹកផុស។ បើធៀបនឹងផែនការឆ្នាំ ២០២១ នោះគឺមានការកើនឡើងលើសការរំពឹងទុក ហើយបានគ្របដណ្តប់នៅតាមរាជធានី និងគ្រប់ខេត្តដោយមានការចូលរួមសហការគ្នាយ៉ាងសស្រាក់សស្រាំពីសំណាក់អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាលជាតិអន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់។

អត្រាលាងសម្អាតដៃនឹងសាប៊ូជាផ្លូវការមានសន្ទុះកើនឡើងដល់ ៨៦,៥% គិតត្រឹមឆ្នាំ២០១៩។ បើផ្អែកតាមនិន្នាការនៃសន្ទុះខាងលើ យើងអាចប៉ាន់ប្រមាណបានថា គិតត្រឹមដំណាច់ឆ្នាំ២០២២ នេះ កម្ពុជា សម្រេចបានអត្រាគ្របដណ្តប់ ៩៦% នៃខ្នងផ្ទះជនបទ មានកន្លែងលាងសម្អាតដៃ។ ល្បឿននៃការផ្លាស់ប្តូរឥរិយាបទលាងសម្អាតដៃនឹងសាប៊ូ កំពុងមានសន្ទុះកើនឡើងលឿនជាងផែនការសកម្មភាពជាតិដែលបានគ្រោងទុក។ តាមនិន្នាការនេះ គិតដល់ដំណាច់ឆ្នាំ២០២៣ សង្ឃឹមថានឹងអាចសម្រេចបានរហូតដល់ប្រមាណ ១០០% គឺលើសគោលដៅដែលបានគ្រោងទុក។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទឱ្យកាន់តែប្រសើរឡើងថែមទៀត ក្រសួងបានជំរុញការពង្រឹងសមត្ថភាព និងយន្តការគាំទ្រនានាទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំគោលការណ៍ណែនាំនិងបទដ្ឋានគតិយុត្តនានា រួមមាន គោលការណ៍ណែនាំជាតិស្តីពីការផ្ទៀងផ្ទាត់ស្ថានភាពបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល និងឯកសារអេកិក្រម ស្តីពីទឹកស្អាត និងអនាម័យសម្រាប់ទាំងអស់គ្នា។

## ២. ៣. ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

កម្មវិធីនេះ សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ក្រសួងបានផ្តួចផ្តើមគំនិតឱ្យបង្កើតការងារ មុខរបរ សហគ្រិនភាព ក៏ដូចជាសកម្មភាពសេដ្ឋកិច្ចនានា ក្រោមរូបភាពចម្រុះដោយមានទាំងមុខរបរកសិកម្ម និងមុខរបរមិនមែនកសិកម្មនៅតាមសហគមន៍ ដែលបាននិងកំពុងចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ ក៏ដូចជាកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតំបន់ជនបទ។ បន្ថែមពីលើនេះ ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ បានផ្តល់ឱ្យគ្រួសារនីមួយៗទទួលបានប្រាក់ចំណូលបន្ថែម និងបានប្រែក្លាយសង្គមជនបទមានភាពសុខដុមរមនា កាត់បន្ថយការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬឆ្លងដែនដោយប្រថុយប្រថានទៅប្រទេសដទៃ និងជំរុញឱ្យមានការផ្លាស់ប្តូរជីវភាពរស់នៅដោយផ្ទាល់របស់ប្រជាជននៅតំបន់ជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន និងឈានទៅប្រែក្លាយរបៀបរបបនៃការរស់នៅឱ្យមានលក្ខណៈកាន់តែស៊ីវិល័យប្រហាក់ប្រហែលនឹងទីក្រុងដែរ។

ទន្ទឹមនឹងនេះ សហគមន៍ជនជាតិដើមភាគតិចក៏ទទួលបាននូវការយកចិត្តទុកដាក់ ក្នុងការអភិវឌ្ឍ

ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយពួកគាត់មានសិទ្ធិពេញលេញក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនានា ក្នុងការកសាងគោលនយោបាយជាតិ និងវិធានការសង្គម ដើម្បីឱ្យពួកគាត់អាចបំពេញនូវសេចក្តីត្រូវការចាំបាច់សម្រាប់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ គោរពអត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ ភាសា និងប្រពៃណី។

ក្រសួងអភិវឌ្ឍន៍ជនបទបាននិងបន្តអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៣ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ និងកាត់បន្ថយគម្លាតរវាងទីប្រជុំជន និងជនបទ។ ក្នុងឆ្នាំ២០២២ នេះ ក្រសួងអនុវត្តសកម្មភាពការងារសម្រេចគោលដៅបានចំនួន ៩១,៩% នៃផែនការឆ្នាំ។ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១ ក្រសួងអនុវត្តបានខ្ពស់ជាងប្រមាណ ៤២,៥% ដែលក្នុងនោះ (១).ការជំរុញការបង្កើតការងារ និងមុខរបរនៅជនបទទទួលបាន ៧៨,៦% នៃផែនការ មានការកើនឡើង ៤៣,៦% ធៀបនឹងឆ្នាំ២០២១ (២).ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទទទួលបាន ៨៧,៥% មានការកើនឡើង ៤៥,៥% ធៀបនឹងឆ្នាំ២០២១ (៣).ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញមូលដ្ឋានទទួលបាន ៩៣,១% មានការកើនឡើងរហូតដល់ ៨០,១% ធៀបនឹងឆ្នាំ២០២១ (៤).ការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទទទួលបាន ៩៤,៦% មានការកើនឡើងរហូតដល់ ៥៨,៦% ធៀបនឹងឆ្នាំ២០២១(៥).ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច ទទួលបាន ៨៩% មានការកើនឡើងរហូតដល់ ២៩% ធៀបនឹងឆ្នាំ២០២១ និង(៦).ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនជនបទ ដោយមន្ទីរជំនាញទាំង ២៥ ទទួលបាន ១០០% មានការកើនឡើងរហូតដល់ ៣៩% ធៀបនឹងឆ្នាំ២០២១។

## ២.៤. ការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

ក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងក្រសួង គាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សនិងអភិបាលកិច្ចល្អ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ សំដៅរួមចំណែកក្នុងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់ដទៃទៀតឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ សមត្ថភាពរបស់ស្ថាប័ន រួមនឹងសមត្ថភាពរបស់មន្ត្រីរាជការមានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាព។ ការរៀបចំផែនការ ការគ្រប់គ្រងនិងការប្រើប្រាស់ថវិកា ត្រូវបានរៀបចំប្រកបដោយគុណភាព និងកាន់តែប្រសើរឡើង ស្របតាមគោលការណ៍ណែនាំ ក៏ដូចជាបទដ្ឋានគតិយុត្តដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។

កម្មវិធីពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅក្នុងឆ្នាំ២០២២ អនុវត្តសកម្មភាពការងារទទួលបានលទ្ធផលប្រមាណ ១០០% នៃផែនការឆ្នាំ។ ក្រសួងអភិវឌ្ឍន៍ជនបទ សម្រេចបានសមិទ្ធផលធំៗជាច្រើន និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសក្នុងដំណាក់កាលទី៣+២ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

ស្តែងចេញពីគោលនយោបាយខាងលើ ក្រសួងបានរៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិលឆ្នាំ(២០២១-២០២៣)ដោយសម្រេចបានគម្រោងវិនិយោគសរុបចំនួន ២៥គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ៥៦៦ ៩៩១ លានរៀល សម្រាប់រយៈពេល ៣ឆ្នាំ (២០២១-២០២៣)ដោយក្នុងនោះគម្រោងកំពុងដំណើរការមានចំនួន ១០គម្រោង មានទឹកប្រាក់សរុបចំនួន ៣៧៥ ៧១១ លានរៀល

សម្រាប់ឆ្នាំ ២០២១-២០២៣ និងទឹកប្រាក់ចំនួន ៥៨ ០៣៨ លានរៀល សម្រាប់ឆ្នាំ២០២២។

គម្រោងវិនិយោគសាធារណៈ ក្រោមជំនួយហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទាំងទ្វេភាគី និងពហុភាគី បានជួយជំរុញការអភិវឌ្ឍនៅតំបន់ជនបទឱ្យមានសន្ទុះយ៉ាងលឿន ពិសេសបានរួមចំណែកអភិវឌ្ឍន៍លើផ្នែកហេដ្ឋារចនាសម្ព័ន្ធរឹងនិងទន់ និងបានលើកកម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទបានល្អប្រសើរឡើងជាបន្តបន្ទាប់។ ជាមួយគ្នានេះ ក្រសួងបានយកចិត្តទុកដាក់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ ដោយបានធ្វើសមាហរណកម្មថវិកាមូលធន និងថវិកាចរន្តបញ្ចូលគ្នាតាមកម្មវិធីអនុកម្មវិធី និងរក្សាបានគម្លាតរវាងថវិកាកម្មវិធីប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ បានក្នុងអត្រា ៨% ដែលអាចឆ្លើយតបបាននឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានកំណត់ក្នុងរង្វង់១០%។

ទន្ទឹមនឹងនេះ ក្រសួងបានរៀបចំសៀវភៅគោលការណ៍ណែនាំការគ្រប់គ្រងថវិកាកម្មវិធី និងអនុកម្មវិធីឆ្នាំ២០២២ ដើម្បីផ្តល់នូវការអនុវត្តថវិកាឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព រក្សាបានតុល្យភាពនៃលំហូរសាច់ប្រាក់ និងធានានិរន្តរភាពការអនុវត្តផែនការសកម្មភាពពីដើមឆ្នាំដល់ចុងឆ្នាំ។ ក្នុងការវិភាជន៍កញ្ចប់ថវិកាប្រចាំឆ្នាំ ក្រសួងបានបង្កើតក្រុមការងារថវិកាដើម្បីផ្តល់ការណែនាំរៀបចំ និងបែងចែកកញ្ចប់ថវិកាទៅតាមកម្មវិធីអាទិភាពនីមួយៗរបស់ក្រសួង។ ក្នុងឆ្នាំ២០២២ នេះ ក្រសួងបានរៀបចំសិក្ខាសាលាពាក់ព័ន្ធនឹងការងារថវិកាចំនួន ៨លើក បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទចំនួន ៤៣កិច្ចព្រមព្រៀង និងបានចុះពិនិត្យសមិទ្ធផលការងាររបស់អង្គការចំនួន ៣៣ (**ភ្ជាប់ជូនក្នុងតារាងឧបសម្ព័ន្ធទី៣**)។ ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចអនុវត្តបាន ១០០% ធៀបនឹងផែនការឆ្នាំ ក្នុងនោះបានចុះធ្វើសវនកម្មនៅអង្គភាពចំនួន ២៧ អង្គភាព រួមមាន មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តចំនួន ២៥ និងគម្រោងចំនួន ០២, បានតាមដានអនុសាសន៍សវនកម្មនៅ ១៧ សវនដ្ឋាន រួមមាន មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តចំនួន ១៦ និងគម្រោងចំនួន ០១, បានធ្វើសិក្ខាសាលាតាមអនឡាញ ០១ លើក ដែលមានសិក្ខាកាមចូលរួមពីមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តទាំង ២៥ បានចុះធ្វើអធិការកិច្ចនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តចំនួន ១៦ និងបានចុះផ្សព្វផ្សាយនីតិវិធីអធិការកិច្ចបានចំនួន ៤ ខេត្ត។ ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ការងារជនមានពិការភាព និងការងារយេនឌ័រ អនុវត្តសកម្មភាពបាន ១០០% សេវាគាំទ្រគោលនយោបាយអនុវត្តសកម្មភាពបាន ១០០% ក្នុងនោះសកម្មភាពសេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបាន ៩៦,៤%ការជួសជុលថែទាំអគាររដ្ឋបាល ការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា និងការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា សម្រេចបាន ១០០%។

## ៣. បញ្ហា និងការប្រឈម

ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បាននិងកំពុងជួបប្រទះនូវបញ្ហាមួយចំនួន ដូចជា ជំងឺកូវីដ-១៩ នៅតែបន្តជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាជន, ការប្រែប្រួលអាកាសធាតុបាននិងកំពុងបង្កផលប៉ះពាល់ដោយផ្ទាល់លើហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលទាមទារនូវនវានុវត្តន៍ និងបង្កើនការចំណាយធនធានជាច្រើន, ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅតែជាបញ្ហាចម្បងដែលនាំឱ្យផ្លូវជនបទងាយទទួលរងការខូចខាតជាបន្តបន្ទាប់ ខណៈដែលយានយន្តមួយចំនួនគេចពីការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅតាមបណ្តាផ្លូវជាតិ និងផ្លូវខេត្តទៅផ្លូវជនបទ, ការចាក់បំពេញដីក្នុងទីធ្លាផ្ទះ ឬដីភូមិ ដែលស្ថិតនៅអមសងខាងផ្លូវឡើងខ្ពស់ ដោយពុំបានរៀបចំប្រព័ន្ធលូ

ប្រឡាយ ឬស្នាមភ្លោះសម្រាប់បង្ហូរទឹកឱ្យបានត្រឹមត្រូវ បណ្តាលឱ្យផ្លូវដក់ទឹកនិងឆាប់រងការខូចខាត, ការធ្លាក់ចុះនៃវត្ថុធាតុដើម ពោលគឺដីល្បាយក្រួសសម្រាប់ផ្គត់ផ្គង់ការងារសាងសង់ ថែទាំ ជួសជុល និងកែលម្អលើកកម្រិតផ្លូវជនបទបាននិងកំពុងបង្កផលប៉ះពាល់ដោយផ្ទាល់ដល់គុណភាព តម្លៃនៃការចំណាយធនធាន និងអាយុកាលនៃការប្រើប្រាស់ផ្លូវជនបទ, តម្រូវការសម្រាប់ការងារថែទាំ ជួសជុល និងកែលម្អលើកកម្រិតផ្លូវជនបទ មានការកើនឡើងរហូតដល់ប្រវែង ៤៧ ៩២០ គ.ម គិតត្រឹមឆ្នាំ២០២២ ឯលទ្ធភាពដែលក្រសួងអាចថែទាំ និងជួសជុលផ្លូវជនបទ បានត្រឹមតែប្រវែងប្រមាណ ៤ ២១៣ គ.ម ស្មើនឹង ៩% ក្នុងមួយឆ្នាំនៃប្រវែងផ្លូវសរុប ដែលបណ្តាលឱ្យផ្លូវងាយរងការខូចខាតកាន់តែធ្ងន់ធ្ងរ ហើយអាយុកាលនៃការប្រើប្រាស់ផ្លូវក៏កាន់តែខ្លីផងដែរ។ កត្តាស្ថានភាពភូមិសាស្ត្រ ដូចជា ភូមិ ឬ/និង ឃុំមួយចំនួនត្រូវបានខណ្ឌចែកគ្នាដោយទន្លេ ព្រែក ឬស្ទឹង កត្តានេះ នាំឱ្យប្រជាពលរដ្ឋដែលរស់នៅសងខាងទន្លេមានការលំបាក ក្នុងការប្រាស្រ័យទាក់ទងគ្នា ក៏ដូចជាជួបប្រទះការលំបាកក្នុងការធ្វើសកម្មភាពធុរកិច្ចជាមួយគ្នា ខណៈដែលអត្រាតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទបច្ចុប្បន្នមានប្រមាណជា ៩០% ប៉ុណ្ណោះ។ ភាពជាម្ចាស់និងកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការចូលរួមថែទាំសមិទ្ធផលនានាពិសេសផ្លូវជនបទ នៅមានកម្រិតនៅឡើយ ដោយសារពួកគាត់យល់ថា សមិទ្ធផល និងកាតព្វកិច្ចថែទាំ ជួសជុល និងសាងសង់ផ្លូវទាំងអស់ជាកិច្ចការរបស់រដ្ឋ។

អត្រាគ្របដណ្តប់ទឹកស្អាត និងអនាម័យក្នុងតំបន់លិចទឹក តំបន់ខ្វះប្រភពទឹក បាននិងកំពុងបង្កផលប៉ះពាល់ដល់អត្រាកំណើនអត្រាគ្របដណ្តប់ទឹកស្អាត និងអនាម័យ។ វិសមភាពនៃការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យរវាងគ្រួសារដែលមានជីភាពក្រីក្រ គ្រួសារងាយរងគ្រោះ និងគ្រួសារដែលមានជីវភាពធូរធារនិងខុសគ្នាពីតំបន់មួយទៅតំបន់មួយ ។ ការប្រែប្រួលអាកាសធាតុដែលបង្កឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៃសេវាទឹកស្អាត និងអនាម័យ, ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីចំពោះរាជធានី/ខេត្ត មិនទាន់មានភាពរលូន និងសមត្ថភាពនៃការរៀបចំសូចនាករក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយនៅមានកម្រិតនៅឡើយ។

ទន្ទឹមនឹងនេះ ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បាននិងកំពុងជួបប្រទះនូវការប្រឈមមួយចំនួនផងដែរ ដែលទាមទារឱ្យមានដំណោះស្រាយសមស្រប ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងដូចជា ការគ្រប់គ្រងផ្លូវជនបទជាន់គ្នា រវាងដែនសមត្ថកិច្ចនានា បានបង្កផលប៉ះពាល់ដល់ការលើកគម្រោងស្តារ ថែទាំ ជួសជុល និងទប់ស្កាត់រាល់បទល្មើសចរាចរណ៍ផ្សេងៗលើដងផ្លូវ ដើម្បីធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងចីរភាពរបស់ផ្លូវជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទនៅមិនទាន់បានបំពេញនីត្យានុកូលភាពជាសមត្ថកិច្ចផ្លូវជនបទ ដូចមានចែងក្នុងច្បាប់ស្តីពីផ្លូវថ្នល់ និងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅឡើយ ហើយក៏មិនអាចចាត់វិធានការផាកពិន័យ រឹបអូស ឬឃាត់ទុកនូវបណ្តាយានយន្តដែលដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់បានដែរ។

កង្វះធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ពីថវិការដ្ឋ និងការថយចុះនៃហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ជាបន្តបន្ទាប់ ជាពិសេសជំនួយឥតសំណង ពុំអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែង ក្នុងការស្តារ ថែទាំ ជួសជុល និងកែលម្អលើកកម្រិតផ្លូវជនបទនៅឡើយ។ ការវិនិយោគសេវាអនាម័យទាំងវិស័យសាធារណៈ វិស័យឯកជន និងជំនួយសហប្រតិបត្តិការពីអង្គការដៃគូបានធ្លាក់ចុះដោយសារត្រូវបង្វិលទុនវិនិយោគមួយភាគធំទៅអន្តរាគមន៍ឆ្លើយតប និងទប់ស្កាត់វិបត្តិនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩, កង្វះថវិកាក៏ជាការប្រឈមផងដែរ ក្នុងការពន្លឿនការចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច ការធានាចំណាយត្រូវ

ការពេលវេលាច្រើនសម្រាប់ដំណើរការឯកសារនីមួយៗ ការទូទាត់ថវិកាយឺតយ៉ាវ ការទម្លាក់ថវិកាបដិភាគយឺតយ៉ាវបានបង្កជាឧបសគ្គដល់ការអនុវត្តគម្រោងដៃគូអភិវឌ្ឍន៍មួយចំនួន។

កង្វះធនធានមនុស្ស និងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិនៅមានកម្រិត ក្នុងការពង្រឹង និងពង្រីកសេវាទឹកស្អាត និងអនាម័យជនបទ ដើម្បីដឹកនាំសម្របសម្រួលក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួនជាពិសេសនៅរដ្ឋបាលស្រុក/ក្រុង/ខណ្ឌ ដែលស្ថិតក្នុងដំណាក់កាលអន្តរកាលនៃកំណែទម្រង់វិមជ្ឈការ។ ការគាំទ្រវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ នៅមិនទាន់ស្របតាមតំរូវការរួមជាមួយនឹងការខ្វះខាតទីផ្សារសម្រាប់កសិករ។ ការកំណត់តម្រូវការអាទិភាព និងការរៀបចំផែនការអភិវឌ្ឍន៍ភូមិរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិនៅមានកម្រិត។ ចំណេះដឹង និងការចូលរួមរបស់ជនជាតិដើមភាគតិចមិនទាន់បានទូលំទូលាយនៅឡើយ។

## ៤.វិធានការដោះស្រាយ

ដើម្បីដោះស្រាយការប្រឈមខាងលើ ក្រសួងបាននិងកំពុងរៀបចំវិធានការដូចតទៅ (១).កំណត់វិធានផាកពិន័យចំពោះបទល្មើសដឹកលើសទម្ងន់លើផ្លូវជនបទ (២).រៀបចំផែនការយុទ្ធសាស្ត្រវិស័យផ្លូវជនបទឱ្យមានសង្គតិភាពនឹងគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ ២០២៣-២០៣៥ (៣).សាងសង់ផ្លូវជនបទធន់នឹងការប្រែប្រួលអាកាសធាតុ (៤).កំណត់អត្តសញ្ញាណផ្លូវជនបទដោយដាក់លេខសម្គាល់ផ្លូវ (៥).រៀបចំផែនការថវិកាឱ្យបានសមស្របតាមតម្រូវការជាអាទិភាពរបស់ប្រជាជន (៦).ជំរុញការងាររៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ ដើម្បីចៀសវាងជាន់ខ្សែផ្លូវគ្នាវាងសមត្ថកិច្ចដទៃ(៧).កំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ទឹកស្អាតនិងអនាម័យជនបទ (៨).កំណត់វិធានបច្ចេកទេសសមស្របតាមតម្រូវការភូមិសាស្ត្រ ប្រជាសាស្ត្រ ដោយសាងសង់ប្រភពទឹកឱ្យមាននិរន្តភាព (៩).ណែនាំប្រជាជនឱ្យយល់ដឹងពីការប្រើប្រាស់ ថែទាំប្រភពទឹកទាំងនោះ ពិសេសអាជ្ញាធរដែនដីដែលត្រូវទទួលខុសត្រូវបន្តក្រោយសាងសង់រួច (១០).ណែនាំបច្ចេកទេសសាងសង់បង្គន់លើទឹកប្រកបដោយគុណភាព (១១).អប់រំប្រជាជនឱ្យយល់ដឹងពីបរិស្ថាន ការសម្អាតជុំវិញលំនៅឋានក្នុងភូមិ ដើម្បីបង្កើនសុខុមាលភាព (១២).រៀបចំគោលនយោបាយអភិវឌ្ឍន៍សហគមន៍ (១៣).ផ្តល់យោបល់ដល់សហគមន៍ផលិតតាមតម្រូវការទីផ្សារ និងមានលក្ខណៈប្រមូលផ្តុំទ្រង់ទ្រាយធំដើម្បីជានាទីផ្សារ និងបង្កើនប្រាក់ចំណូល (១៤).ជំរុញបង្កើនសហគមន៍សន្សំប្រាក់ (១៥).ណែនាំនិងបណ្តុះបណ្តាលរបៀបធ្វើអាជីវកម្មខ្នាតតូច និងមធ្យម (១៦).បង្កើតមជ្ឈមបណ្ឌលបណ្តុះបណ្តាលចល័ត នៅតំបន់ដាច់ស្រយាលដើម្បីគាំទ្រដល់កសិករក្រីក្រនៅជនបទ (១៧).បណ្តុះបណ្តាលជនជាតិដើមភាគតិចឱ្យមានជំនាញបំណិនជីវិត និង(១៨).រៀបចំមជ្ឈមណ្ឌលអភិរក្សជនជាតិដើមភាគតិច។

## ៥. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៣

ផ្អែកលើគោលនយោបាយ បណ្តាបញ្ហា និងការប្រឈមខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវបណ្តាសកម្មភាពការងារសម្រាប់ឆ្នាំ ២០២៣ ដូចតទៅៈ

**កម្មវិធីទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ ៖** បន្តបង្កើនការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ផ្លូវជនបទបានយូរអង្វែង និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅតំបន់ជនបទ ដើម្បីឈានទៅសម្រេចគោលដៅប្រែក្លាយការស្ថាបនា ស្តារ និងកែលម្អផ្លូវជនបទ ពីផ្លូវដី និងផ្លូវល្បាយក្រួសទៅជាកៅស៊ូ

ពីរជាន់ ឬបេតុងដែលធន់នឹងការប្រែប្រួលអាកាសធាតុ ឱ្យបានប្រវែង ១ ៩០០ គ.ម, ការថែទាំជាលក្ខណៈខួប លក្ខណៈប្រចាំ និងបន្ទាន់ឱ្យបានប្រវែង ៤ ៨៧១ គ.ម។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងអនុវត្តសកម្មភាពការងារទាំងឡាយ ដូចខាងក្រោម៖

- បន្តការងាររៀបចំផែនការ និងចុះសិក្សាគម្រោងស្ថាបនា ស្តារឡើងវិញ កែលម្អ ជួសជុល និងថែទាំផ្លូវជនបទ
- បន្តការថែទាំ និងជួសជុលផ្លូវជនបទលក្ខណៈខួប លក្ខណៈប្រចាំ និងជួសជុល
- បន្តការងារស្ថាបនា កែលម្អ និងស្តារឡើងវិញផ្លូវជនបទ និងសំណង់សិល្បការ្យគ្រប់ប្រភេទ
- បន្តការងារធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ
- បន្តចុះត្រួតពិនិត្យ និងវាយតម្លៃ គម្រោងស្ថាបនា កែលម្អ ស្តារឡើងវិញ និងថែទាំផ្លូវជនបទ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលក្ខណៈបច្ចេកទេសស្ថាបនា កែលម្អ និងស្តារឡើងវិញផ្លូវជនបទដល់អ្នកទទួលការ
- រៀបចំផែនការថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា
- បន្តកិច្ចសហការប្រតិបត្តិការជាមួយគម្រោងដៃគូដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ។

**កម្មវិធីទី២៖ ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ** ដោយមានគោលដៅសម្រេចឱ្យបានអត្រាគ្របដណ្តប់សេវាទឹកស្អាតនិងអនាម័យជនបទ ៩០% នៅឆ្នាំ២០២៣ ១០០% នៅឆ្នាំ ២០២៥ និងបន្តអនុវត្តផែនការសុវត្ថិភាពទឹកនៅឆ្នាំ ២០២៥- ២០៣០ ខណៈឆ្នាំ២០២២ នេះក្រសួងសម្រេចបានជាង ៨០% នៃអត្រាទឹកស្អាតជនបទ និងអនាម័យជនបទ។ ខេត្តចំនួន ៦ ក្លាយជាខេត្ត ODF នៅឆ្នាំ ២០២៣ ខណៈបច្ចុប្បន្នក្រសួងសម្រេចបាន ៣ ខេត្តរួចហើយ។ ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ ក្រសួងបានកំណត់វិធានការមួយចំនួន ដូចខាងក្រោម ៖

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការ សម្របសម្រួល និងកៀរគរធនធាន ដើម្បីពង្រីកវិសាលភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ ឱ្យកាន់តែខ្លាំងក្លានិងមានប្រសិទ្ធភាពថែមទៀត ដោយផ្តោតលើវិធានការសេដ្ឋកិច្ច វិធានការរដ្ឋបាល និងវិធានការអប់រំ ដើម្បីឆ្លើយតបនឹងបរិបទជាក់ស្តែងនៃសហគមន៍នីមួយៗ
- បន្តជំរុញ និងលើកទឹកចិត្តរាជធានី ខេត្ត ដែលមានអត្រាគ្របដណ្តប់អនាម័យខ្ពស់ ឱ្យក្លាយជាខេត្តដែលបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ១០០% និងលើកទឹកចិត្តខេត្តដែលមានកម្រិតកំណើនអនាម័យទាប ខិតខំរកលទ្ធភាពគ្រប់បែបយ៉ាងក្នុងការគាំទ្រ និងជំនះនូវកត្តារាំងស្ទះ ធ្វើយ៉ាងណាឱ្យសន្ទុះអនាម័យតាមខេត្តទាំងនោះមានការកើនឡើងល្អប្រសើរជាងមុនតាមរយៈការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាជាប្រចាំពីបណ្តាខេត្តឈានមុខដែលមានបទពិសោធន៍ និងកំណើនអនាម័យខ្ពស់
- បន្តលើកកម្ពស់ការលាងសម្អាតដៃនឹងសាប៊ូ ឱ្យមានកម្រិតកាន់តែខ្ពស់ថែមទៀតទាំងនៅក្នុងសហគមន៍ នៅតាមសាលារៀន និងស្ថាប័នសាធារណៈទាំងអស់ តាមរយៈការអប់រំនិងបង្កើតកន្លែងលាងដៃ រួមទាំងផ្គត់ផ្គង់សម្ភារលាងសម្អាតដៃ
- បន្តកៀរគរធនធានដើម្បីពន្លឿនអត្រាគ្របដណ្តប់អនាម័យនៅជនបទ ជាពិសេសជួយដល់គ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះនានា ដើម្បីបង្កលទ្ធភាពឱ្យពួកគេទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

- បន្តលើកកម្ពស់ការចូលរួមពីវិស័យឯកជនក្នុងការពន្លឿនសេវាគ្រប់ដណ្តប់អនាម័យជាមូលដ្ឋាននៅជនបទ
- សហការជាមួយអង្គការដៃគូ ចុះពិនិត្យតំបន់គោលដៅ ចៀសវាងការជាន់គ្នា និងដើម្បីពង្រាយធនធានទៅខេត្តខ្សត់ខ្សោយដែលមានតម្រូវការខ្ពស់
- បន្តសហការជាមួយអង្គការដៃគូ ដើម្បីគាំទ្រការងារគោលនយោបាយ និងពង្រឹងសមត្ថភាពស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- រៀបចំពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ ។

**កម្មវិធីទី៣៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ** សំដៅជានាជំរុញកំណើនសេដ្ឋកិច្ចតាមគ្រួសារ នៅតំបន់ជនបទ ធ្វើឱ្យសហគមន៍មានបំណិនជីវិត អាចបង្កើតជំនាញផ្ទាល់ខ្លួន បង្កើតមុខរបរនិងបង្កើនប្រាក់ចំណូល ជំរុញប្រក្រតីភាពនៃ គ.អ.ភ បង្កើនការអភិវឌ្ឍសហគមន៍ជនបទបែបចម្រុះនិងកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច និងចូលរួមដោះបញ្ហាការប្រឈមរបស់ជនជាតិដើមភាគតិច។ ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ ក្រសួងបានកំណត់វិធានការមួយចំនួន ដូចខាងក្រោម ៖

- ជំរុញដំណើរការគាំទ្រសហគមន៍សន្សំប្រាក់នៅតាមបណ្តារាជធានី ខេត្ត
- ជំរុញការងារអភិវឌ្ឍន៍ និងសាងសង់ផ្សារជនបទនៅតាមបណ្តាខេត្តគោលដៅ និងរៀបចំព្រឹត្តការណ៍តាំងពិព័រណ៍ផលិតផលជនបទ
- ជំរុញការផ្តល់ឥណទាន និងប្រមូលត្រឡប់មកវិញឱ្យមានប្រសិទ្ធភាព
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូ វិស័យឯកជន និងគម្រោងនានា
- បន្តរៀបចំឯកសារគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តតាមវិស័យ
- បន្តពង្រឹងការតាមដាន និងវាយតម្លៃ ដើម្បីជានាប្រសិទ្ធភាពនៃការអនុវត្តការងារ
- បន្តពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមរយៈការបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការបញ្ជូនមន្ត្រីឱ្យទៅចូលរួមកម្មវិធីបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស
- សម្របសម្រួលជាមួយមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ឱ្យបន្តខិតខំស្វែងរកកិច្ចសហការ និងការគាំទ្រពីគម្រោងកម្មវិធី និងអង្គការនានា ក្នុងការពង្រឹងសមត្ថភាព គ.អ.ភ
- បន្តគាំទ្រដល់គម្រោងអភិវឌ្ឍន៍ភូមិចម្រុះ ដើម្បីអភិវឌ្ឍន៍ទៅជាភូមិគំរូ
- បន្តបណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត៍
- បន្តបណ្តុះបណ្តាលស្តីពីការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍
- បន្តតាមដានការអនុវត្តសកម្មភាពបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
- សម្របសម្រួល និងសហការអនុវត្តគម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍
- ពន្លឿនក្នុងការចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចចំនួន ១៣ភូមិ និងសម្របសម្រួលរៀបចំបទបញ្ជាផ្ទៃក្នុងសហគមន៍ចំនួន ២០ភូមិ
- បន្តចុះសិក្សាភូមិគោលដៅបន្ថែមទៀត ដើម្បីរៀបចំចុះវាយតម្លៃកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច

- បន្តចុះរៀបចំកំណត់ទីតាំងភូមិសាស្ត្រគោលរបស់សហគមន៍ជនជាតិដើមភាគតិចនៅខេត្ត និង សហគមន៍គោលដៅឱ្យបានចំនួន ៤ខេត្ត និង ៧សហគមន៍
- បណ្តុះបណ្តាលប្រជាពលរដ្ឋនៅជនបទឱ្យមានបំណិនជីវិតធន់នឹងការប្រែប្រួលអាកាសធាតុ
- រៀបចំសិក្ខាសាលាចែករំលែកចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍អំពីការអភិវឌ្ឍជនបទ
- បន្តផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាជនជនបទ

**កម្មវិធីទី៤៖ ការងារពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ** ជាកម្មវិធីសម្រាប់គាំទ្រដល់កិច្ចដំណើរការ ចរន្តទាំងមូលរបស់ក្រសួង ក្នុងនោះផ្សព្វផ្សាយការណែនាំបទដ្ឋានគតិយុត្ត គោលនយោបាយ និងសេចក្តីណែនាំនានារបស់រាជរដ្ឋាភិបាលជូនដល់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួង រៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធីប្រចាំឆ្នាំ របាយការណ៍វាយតម្លៃសមិទ្ធកម្មនិងហិរញ្ញវត្ថុ នីតិវិធីប្រើប្រាស់ថវិកា លទ្ធកម្ម ការទូទាត់ថវិកា របាយការណ៍សវនកម្ម អធិការកិច្ច តាមដាន ត្រួតពិនិត្យនិងវាយតម្លៃរួមទាំងការងារយេនឌ័រ ជនពិការ ការកែទម្រង់ផ្សេងៗ។ល។ ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ ក្រសួងបានកំណត់វិធានការមួយចំនួន ដូចខាងក្រោម ៖

- បន្តរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២៣-២០៣២
- បន្តកែសម្រួល ផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី ក្នុងបរិបទថ្មីនៃការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ទី៣+២ និងដំណាក់កាលទី៤ "ថវិកាសមិទ្ធកម្ម"
- រៀបចំអង្គភាពថវិកាមួយចំនួនក្លាយជាអង្គភាពអាណាប័កផ្ទេរសិទ្ធស្របតាមអនុក្រឹត្យលេខ ២៤២ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១
- ផ្លាស់ប្តូរទម្រង់បែបបទនៃការរៀបចំថវិកាកម្មវិធីមកជាថវិកាសមិទ្ធកម្ម
- រៀបចំសៀវភៅគ្រប់គ្រងហិរញ្ញវត្ថុ (Financial Managemernt Manual)
- បង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យនិងវាយតម្លៃគម្រោងទាំងថវិការដ្ឋ និងថវិកាដៃគូ
- កែសម្រួលយន្តការ និងប្រព័ន្ធគ្រប់គ្រង និងអនុវត្តគម្រោងដៃគូឡើងវិញឱ្យប្រសើរឡើង
- បន្តអនុវត្តវិធាន FMIS លើមុខងារថ្មីមួយចំនួនទៀត
- បន្តរៀបចំទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធ SAMIS
- រៀបចំសវនកម្មតាមប្រព័ន្ធព័ត៌មានវិទ្យា (ICT Audit)
- បណ្តុះបណ្តាលជំនាញបច្ចេកវិទ្យានវានុវត្តន៍ឈានទៅអនុវត្តបដិវត្តឧស្សាហកម្មទី៤.០
- បន្តជំរុញការងារយេនឌ័រ
- បន្តការងារកែលម្អការគ្រប់គ្រងមន្ត្រី
- បន្តការងារវិមជ្ឈការនិងវិសហមជ្ឈការ
- បន្តពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមរយៈការបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការបញ្ជូនមន្ត្រីឱ្យទៅចូលរួមកម្មវិធីបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស
- សិក្សាស្រាវជ្រាវ និងចងក្រងកម្មវិធីបណ្តុះបណ្តាលមន្ត្រីរាជការ ព្រមទាំងផលិតឯកសារមេរៀន និង
- រៀបចំពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តពាក់ព័ន្ធដំណើរការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

## ៦.សន្និដ្ឋាន

កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានមតិជាតិ និងអន្តរជាតិកត់ត្រាក្នុងប្រវត្តិសាស្ត្រជាបន្តបន្ទាប់ ពិសេសបន្ទាប់ពីកម្ពុជា បានបញ្ចប់ដោយជោគជ័យនូវកិច្ចប្រជុំអាស៊ានលើកទី៤០ និងកិច្ចប្រជុំពាក់ព័ន្ធលើកទី៤១ នៅរាជធានីភ្នំពេញ ដោយមានប្រទេសមហាអំណាចជាច្រើនចូលរួម ប្រកបដោយផ្លែផ្កាយ៉ាងល្អ។ ភាពជោគជ័យនេះបានបញ្ជាក់ពីសុខសន្តិភាព ស្ថិរភាពនយោបាយក្នុងប្រទេស គួបផ្សំនឹងមានភាពស៊ាំនឹងជំងឺកូវីដ-១៩ ក្នុងប្រទេសផងដែរ។ ក្នុងដំណាក់កាលនេះ ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័សដែលបាននាំនូវកំណើនសេដ្ឋកិច្ចកើនដល់ ៥,១% ក្នុងឆ្នាំ២០២២ និងបានបង្កលក្ខណៈឱ្យប្រជាជននៅទូទាំងប្រទេសទទួលបានជីវភាពរស់នៅល្អប្រសើរ និងសុខភាពត្រូវបានកែលម្អឡើងវិញ។

លទ្ធផលដែលសម្រេចបានខាងលើនេះ គឺអាស្រ័យលើកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គមដោយមានការគាំទ្រ និងចូលរួមយ៉ាងពេញទំហឹងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញនូវចក្ខុវិស័យ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដ៏ត្រឹមត្រូវច្បាស់លាស់ និងឆ្លើយតបចំគោលដៅទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ និងលើកកម្ពស់ឧត្តមប្រយោជន៍ជាតិ។ ដោយផ្អែកលើលទ្ធផលជាស្នាដៃដ៏ធំធេងខាងលើ និងដោយមានកត្តារួមផ្សំជាច្រើន នៅឆ្នាំ២០២៣ ខាងមុខនេះ ក្រសួងនឹងបន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរយៈពេល ៥ឆ្នាំ សម្រាប់នីតិកាលទី៧ ក្នុងការបន្តបេសកកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ រួមចំណែកកាត់បន្ថយភាពក្រីក្រ ប្រែក្លាយប្រទេសកម្ពុជាជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់ ឆ្នាំ២០៥០៕

**រដ្ឋមន្ត្រី**

# តារាងឧបសម្ព័ន្ធទី ១

# លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០២២ តាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព

| ល.រ | បរិយាយ | លទ្ធផលសម្រេចបាន | ឯកតា | ផ្សេងៗ |
|---|---|---|---|---|
| ១ | **កម្មវិធីទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍** | | | |
| ១.១ | អនុកម្មវិធីទី១៖ ការជួសជុល និងរក្សាគុណភាពផ្លូវជនបទ | | | |
| ១.១.១ | ចង្កោមសកម្មភាពទី១៖ ការថែទាំផ្លូវជាលក្ខណៈខួប | ៣៥៣ | គ.ម | |
| | -សកម្មភាពទី ១៖ ថែទាំផ្លូវក្រាលល្បាយក្រួស | ៣២៥ | គ.ម | |
| | -សកម្មភាពទី ២៖ ថែទាំផ្លូវក្រាលកៅស៊ូ | ២៨ | គ.ម | |
| ១.១.២ | ចង្កោមសកម្មភាពទី២៖ ការថែទាំផ្លូវជាលក្ខណៈប្រចាំ | ៣ ៧០៩ | គ.ម | |
| | -សកម្មភាពទី ១៖ ថែទាំផ្លូវក្រាលល្បាយក្រួស | ២ ៥២២ | គ.ម | |
| | -សកម្មភាពទី ២៖ ថែទាំផ្លូវក្រាលកៅស៊ូ | ១ ១៨៧ | គ.ម | |
| ១.១.៣ | ចង្កោមសកម្មភាពទី៣៖ ការជួសជុលផ្លូវជាលក្ខណៈបន្ទាន់ | ១៥១ | គ.ម | |
| | -សកម្មភាពទី១៖ ជួសជុលផ្លូវរងការខូចខាតមិនអាចចរាចរបានដោយអន្លើៗ | ១៥១ | គ.ម | |
| ១.២ | អនុកម្មវិធីទី២៖ ការពង្រីកវិសាលភាពនៃការស្ថាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ (ជំពូក២១) | | | |
| ១.២.១ | ចង្កោមសកម្មភាពទី១៖ ការស្ថាបនា និងកែលម្អផ្លូវជនបទ | ២៦១ | គ.ម | |
| | -សកម្មភាពទី ១៖ ស្ថាបនាផ្លូវល្បាយក្រួស | ១៣២ | គ.ម | |
| | -សកម្មភាពទី ២៖ ស្ថាបនាផ្លូវកៅស៊ូ និងបេតុង | ១២៩ | គ.ម | |
| ១.២.២ | ចង្កោមសកម្មភាពទី២៖ ការស្ថាបនាសំណង់សិល្បការ្យ | ៣ ០៩៤ | កន្លែង/ស្លាក | |

| ល.រ | បរិយាយ | លទ្ធផលសម្រេចបាន | ឯកតា | ផ្សេងៗ |
|---|---|---|---|---|
| | -សកម្មភាពទី ១៖ ការស្ថាបនាសំណង់សិល្បការ្យ និងស្លាកសញ្ញាចរាចរណ៍ | ៣ ០៩៤ | កន្លែង/ស្លាក | |
| ១.៣ | **អនុកម្មវិធីទី៣៖ ការរៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ** | | | |
| ១.៣.១ | ចង្កោមសកម្មភាពទី១៖ ការរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ | ៤៧ ៩១៩ | គ.ម | |
| | -សកម្មភាពទី ១៖ ការរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ | ៤៧ ៩១៩ | គ.ម | |
| ១.៣.២ | ចង្កោមសកម្មភាពទី២៖ ការរៀបចំផែនទីផ្លូវជនបទ | ៩៣ | ខ្សែ | |
| | -សកម្មភាពទី ១៖ ផែនទីត្រេកខ្សែផ្លូវជនបទ | ៩៣ | ខ្សែ | |
| ១.៤ | **អនុកម្មវិធីទី៤៖ ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទដោយមន្ទីរជំនាញ ២៥** | | | |
| | -សកម្មភាពទី ១៖ ការងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ | ៦៧,៨ | គ.ម | |
| | -សកម្មភាពទី ២៖ ការងារថែទាំ ជួសជុលស្ពាន និងហេដ្ឋារចនាសម្ព័ន្ធជនបទ | ៧៩,៧ | គ.ម | |
| | -សកម្មភាពទី ៣៖ ការងារថែទាំផ្លូវទប់ទល់នឹងការប្រែប្រួលអាកាសធាតុ (ដាំកូនឈើ) | ៣៦ ១៥៩ | ដើម | |
| | -សកម្មភាពទី ៤៖ ការរាប់ចំនួនចរាចរណ៍យានយន្ត | ១៤១ | ខ្សែ | |
| | -សកម្មភាពទី ៥៖ ការសាងសង់ទីទួលសុវត្ថិភាព | ១២ | កន្លែង | |
| | -សកម្មភាពទី ៦៖ ត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើផ្លូវជនបទ | ៩៨ | លើក | |
| គម្រោង | គម្រោងសាច់ប្រាក់ពលកម្ម | ៩១៤ | គ.ម | ថវិកាមិនមែនកម្មវិធី |
| សកម្មភាពទី១ | -ស្ថាបនាផ្លូវក្រាលល្បាយក្រួស | ៣៣៥ | គ.ម | |
| សកម្មភាពទី២ | -ស្ថាបនាផ្លូវដី | ៥៧៩ | គ.ម | |
| ២ | **កម្មវិធីទី២៖ ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ** | | | |
| ២.១ | **អនុកម្មវិធីទី១៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ** | | | |

| ល.រ | បរិយាយ | លទ្ធផលសម្រេចបាន | ឯកតា | ផ្សេងៗ |
|---|---|---|---|---|
| ២.១.១ | ចង្កោមសកម្មភាពទី១៖ ការសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ | ៣០៦ | អណ្តូង | |
| | -សកម្មភាពទី ១៖ សាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ | ៣០៦ | អណ្តូង | |
| ២.១.២ | ចង្កោមសកម្មភាពទី២៖ ការសាងសង់ប្រភពទឹកស្អាតជនបទ | | | |
| | -សកម្មភាពទី ១៖ សាងសង់ស្រះសហគមន៍ | ១០ | ស្រះ | |
| | -សកម្មភាពទី ២៖ សាងសង់អាងត្រងទឹកភ្លៀង | ៤៩ | កន្លែង | |
| | -សកម្មភាពទី ៣៖ សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ | ៥ | កន្លែង | |
| | -សកម្មភាពទី ៤៖ សាងសង់ស្ថានីយ៍ទឹកសហគមន៍ (សម្រាប់ច្រកដបហូប) | ១ | កន្លែង | |
| **២.២** | **អនុកម្មវិធីទី២៖ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ** | | | |
| ២.២.១ | ចង្កោមសកម្មភាពទី១៖ ការបណ្តុះបណ្តាលបច្ចេកទេសថែទាំ និងជួសជុលអណ្តូងទឹក | | | |
